សិក្ខាសាលាផ្លាស់ប្តូរមេរៀនបទពិសោធន៍ លើកទី១
អំពី
មុខងារជាជម្រើស

1st Learning Exchange Workshop
on
Permissive Functions

ថ្ងៃទី ២៧ – ២៨ ខែកក្កដា ឆ្នាំ២០១៧
ខេត្តកែប

27 – 28 July 2017
Kep Province

សិក្ខាសាលាផ្លាស់ប្តូរមេរៀនបទពិសោធន៍
ថ្ងៃទី ២៧ – ២៨ ខែកក្កដា ឆ្នាំ២០១៧
នៅខេត្តកែប

---

១. សេចក្តីផ្តើម

ការផ្តល់សេវាសាធារណៈ គឺជាប្រធានបទមួយដ៏សំខាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសារថា រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានប្រគល់អាណត្តិក្នុងការបម្រើប្រជាពលរដ្ឋ។ ទោះបីស្ថិតនៅក្រោមបរិយាកាសច្បាប់តែមួយ ប៉ុន្តែរដ្ឋបាលថ្នាក់ក្រោមជាតិ(SNA)នីមួយៗមានការប្រតិបត្តិ/អនុវត្ត និងប្រើប្រាស់វិធីសាស្ត្រខុសៗគ្នាក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ចំណុចនេះហើយ ដែលធ្វើឲ្យការផ្លាស់ប្តូរនូវមេរៀនបទពិសោធន៍ពាក់ព័ន្ធទៅនឹងការប្រតិបត្តិ/អនុវត្ត (ទោះជាការប្រតិបត្តិ/អនុវត្តទាំងនោះល្អ ឬមិនល្អក៏ដោយ) រវាងរដ្ឋបាលថ្នាក់ក្រោមជាតិដូចគ្នា និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងថ្នាក់ជាតិមានសារៈប្រយោជន៍យ៉ាងខ្លាំង។ ព្រឹត្តការណ៍នេះមិនគ្រាន់តែជាការផ្តល់ឱកាសដល់រដ្ឋបាលថ្នាក់ក្រោមជាតិបានផ្លាស់ប្តូរ និងចែករំលែកនូវមេរៀនបទពិសោធន៍គ្នាទៅវិញទៅមកជុំវិញការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានផ្តល់ឱកាសផងដែរដល់ថ្នាក់ជាតិក្នុងការសិក្សា និងស្វែងយល់អំពីការរៀបចំតាក់តែងគោលនយោបាយកន្លងមក ថាតើគោលនយោបាយទាំងនោះអាចអនុវត្តបានជោគជ័យកម្រិតណា? និងតើមានបញ្ហាប្រឈម និងការលំបាកអ្វីខ្លះដែលទាមទារឲ្យមានការដោះស្រាយតទៅមុខ?។ ដោយឈរលើមេរៀន និងបទពិសោធន៍ទាំងនោះ ថ្នាក់ជាតិអាចពិភាក្សាដេញដោល ដើម្បីកែសម្រួលគោលនយោបាយដែលបានរៀបចំកន្លងមក និងរិះរកវិធីផ្សេងៗដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយទាំងនោះនៅរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យទទួលបានជោគជ័យ។

ដើម្បីផ្តល់ឱកាសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិបានផ្លាស់ប្តូរ និងចែករំលែកនូវមេរៀនបទពិសោធន៍ពីគ្នាទៅវិញទៅមក កម្មវិធី DAR/GIZ និងលេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំនូវសិក្ខាសាលាលើកទីមួយស្តីពីការផ្លាស់ប្តូរមេរៀនបទពិសោធន៍ នៅ**សណ្ឋាគារ រ៉ាក់រ៉ូយាល់** នៅខេត្តកែប **ចាប់ពី**ថ្ងៃទី២៧–២៨ ខែ កក្កដា ឆ្នាំ២០១៧។ សិក្ខាសាលាសម្រាប់ផ្លាស់ប្តូរ និងចែករំលែកនូវមេរៀនបទពិសោធន៍នេះ គឺជាការចាប់ផ្តើម ដំបូង ដែលសិក្ខាសាលាបែបនេះនឹងត្រូវរៀបចំជាបន្តបន្ទាប់ទៀតនៅក្នុងរយៈពេល១៨ខែខាងមុខនេះ។

២. គោលបំណង

គោលបំណងសំខាន់របស់សិក្ខាសាលាគឺ ៖

១) សិក្សា និងពិភាក្សាអំពីវិធីសាស្ត្រសម្របសម្រួលដើម្បីផ្តល់សេវាឲ្យបានល្អដល់ប្រជាពលរដ្ឋ

២) ផ្លាស់ប្តូរ និងចែករំលែកនូវមេរៀនបទពិសោធល្អៗ និងបញ្ហាប្រឈមនានាពាក់ព័ន្ធទៅនឹងការប្រតិបត្តិ/អនុវត្តក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ

៣) ឆ្លុះបញ្ចាំងអំពីការអនុវត្តន៍គោលនយោបាយនៅថ្នាក់ក្រោមជាតិ

៤) កំណត់ទម្រង់នានាសម្រាប់ផ្លាស់ប្តូរ និងចែករំលែកមេរៀនបទពិសោធន៍ ដើម្បីផ្តល់ឱកាសឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បានចែករំលែក និងផ្លាស់ប្តូរមេរៀនបទពិសោធន៍នានាឲ្យបានទៀងទាត់ (ដូចជាតាមរយៈបណ្តាញព័ត៌មានសង្គមជាដើម)

៣. វិធីសាស្ត្រ

ការប្រតិបត្តិ/ការអនុវត្តនានាពាក់ព័ន្ធទៅនឹងការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋនឹងត្រូវប្រមូលពី បណ្តាស្រុកដៃគូររបស់កម្មវិធី DAR និងក្រុង/ស្រុកមួយចំនួនទៀត។

មុនពេលធ្វើបទបង្ហាញ/ចែករំលែកអំពីការប្រតិបត្តិ/អនុវត្ត និងមេរៀនបទពិសោធន៍ទាំងនោះ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងមុខងារសាធារណៈ នឹងផ្តល់ធាតុចូលខ្លីមួយស្តីពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាក្រុងស្រុក និងរដ្ឋបាលថ្នាក់ក្រោមជាតិ ការអនុវត្តអាណត្តិទូទៅរបស់ក្រុមប្រឹក្សា និងលទ្ធផលរំពឹងទុករបស់ថ្នាក់ជាតិចំពោះថ្នាក់ក្រោមជាតិ។ សារៈសំខាន់នៃការសម្របសម្រួលរវាងអ្នកពាក់ព័ន្ធនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាក៏នឹងត្រូវលើកយកមកបង្ហាញផងដែរ ហើយតំណាងនានានៅថ្នាក់ក្រោមជាតិនឹងត្រូវបានលើកទឹកចិត្តឲ្យបម្រើប្រជាពលរដ្ឋ តាមរយៈការផ្តល់សេវាល្អជូនដល់ពួកគាត់។

នៅក្នុងដំហានទី២ ក្រុងស្រុកមួយចំនួននឹងធ្វើបទបង្ហាញ និងចែករំលែកនូវមេរៀនបទពិសោធនានាដែលកើតមាននៅក្នុងក្រុងស្រុករបស់ខ្លួន។ បទបង្ហាញ និងកិច្ចពិភាក្សា (Panel Discussion) ទាំងនោះនឹងត្រូវរៀបចំឡើងដោយផ្អែកលើបញ្ហាសំណួរ ដែលនឹងអាចជួយដល់ការរៀបចំរចនាសម្ព័ន្ធ និងខ្លឹមសារនៃបទបង្ហាញឲ្យកាន់តែមានភាពច្បាស់លាស់ថែមទៀត។ បទបង្ហាញ និងកិច្ចពិភាក្សា (Panel Discussion) ទាំងនោះនឹងឆ្លុះបញ្ចាំងថា៖ តើត្រូវធ្វើដូចម្តេចដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ?តើត្រូវធ្វើដូចម្តេចដើម្បីកែលម្អការផ្តល់សេវាដល់ប្រជាពលរដ្ឋ? និងតើត្រូវសម្របសម្រួលនិងសហការជាមួយអ្នកពាក់ព័ន្ធណាខ្លះដើម្បីផ្តល់សេវាដល់ប្រជាពលរដ្ឋឲ្យបានកាន់តែល្អប្រសើរថែមទៀត។ អ្នកចូលរួមទាំងអស់ ជាពិសេសអ្នកចូលរួមមកពីរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានលើកទឹកចិត្តឲ្យលើកជាសំណួរផ្សេងៗឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ជាមួយគ្នានេះផងដែរ អ្នកសម្រប

សម្រួលកម្មវិធី (Moderator) ត្រូវជំរុញឲ្យមានការចូលរួមយោបល់ឲ្យបានផុលផុសពីអ្នកចូលរួមទាំងអស់នៅក្នុងដំណើរការពិភាក្សា (Panel Discussion)។ វិធីសាស្ត្រនេះនឹងអាចឲ្យអ្នកចូលរួមប្រើប្រាស់ជាប្រយោជន៍ និងទទួលបាននូវមេរៀនបទពិសោធន៍ថ្មីៗបន្ថែមទៀតសម្រាប់យកទៅអនុវត្តនៅក្នុងក្រុងស្រុករបស់ខ្លួន។

នៅក្នុងជំហ៊ានទី៣ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងមុខងារសាធារណៈនឹងបញ្ជាក់អំពីការគាំទ្ររបស់ខ្លួនចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ។ សំណួរសំខាន់នៃចំណុចនេះរួមមាន៖ តើការគាំទ្រដល់ក្រុមប្រឹក្សា និងរដ្ឋបាលក្រុងស្រុកមានលក្ខណៈដូចម្តេច?និងថាតើពួកគាត់អាចផ្តល់អ្វីបានខ្លះពាក់ព័ន្ធទៅនឹងការផ្តល់អំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាដើម្បីឲ្យពួកគាត់ផ្តល់សេវាបានកាន់តែល្អប្រសើរដល់ប្រជាពលរដ្ឋ? ជាងនេះទៅទៀតនឹងមានការពិភាក្សាផងដែរអំពីវិធីសាស្ត្រដែលថ្នាក់ជាតិអាចគាំទ្រដល់ថ្នាក់ក្រោមជាតិលើការពង្រីកវិសាលភាពនៃការផ្លាស់ប្តូរ និងចែករំលែកមេរៀនបទពិសោធន៍ទៅដល់បណ្តាក្រុងស្រុកផ្សេងៗទៀត ព្រមទាំងវិធីសាស្ត្រក្នុងការប្រមូលផ្តុំក្រុងស្រុកនានាដើម្បីរៀនសូត្រពីគ្នាទៅវិញទៅមកក្នុងគោលបំណងធ្វើឲ្យការផ្តល់សេវាជូនដល់ប្រជាពលរដ្ឋកាន់តែមានភាពប្រសើរឡើង។ នៅក្នុងឱកាសនោះដែរ កម្មវិធី GIZ/DAR នឹងបង្ហាញនូវឧបករណ៍មួយចំនួនសម្រាប់ពង្រីកការផ្លាស់ប្តូរ និងចែករំលែកមេរៀនបទពិសោធន៍។ បន្ទាប់មកនឹងស្នើសុំឲ្យដៃគូរ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ធ្វើការសម្រេចចិត្តលើការប្រើប្រាស់ឧបករណ៍ទាំងនោះ។

៤. រៀបចំ៖

ម៉ោង	ប្រធានបទ	អ្នកទទួលខុសត្រូវ
២៦ កក្កដា ២០១៧	**អ្នកចូលរួមទាំងអស់ធ្វើដំណើរទៅកាន់ខេត្តកែប**	
២៧ កក្កដា ២០១៧		
08:30 – 09:00	កម្មវិធីបើក រៀបចំ៖ និងគោលបំណង	អ្នកកាន់កម្មវិធី
09:00 – 09:15	ការណែនាំខ្លួនរបស់អ្នកចូលរួម	MC និងអ្នកចូលរួម
09:15 – 09:45	ធាតុចូលស្តីពីការផ្តល់សេវាដល់ប្រជាពលរដ្ឋ	NCDD-S / MCS
09:45 – 10:00	យោបល់ សំណួរ និងចម្លើយ	អ្នកចូលរួម
10:00 – 10:15	**សម្រាកពិសារកាហ្វេ**	
10:15 – 11:00	**<u>បទបង្ហាញស្តីពីមេរៀនបទពិសោធ</u>**៖ ការសម្របសម្រួលលើការផ្តល់សេវាដល់ប្រជាពលរដ្ឋ ផ្អែកតាមក្របខ័ណ្ឌនៃការអនុវត្តអណត្តិទូទៅ (មុខងារជាជម្រើស) របស់ក្រុមប្រឹក្សានៅស្រុកកៀនស្វាយ **"ការដោះស្រាយក្លិនស្អុយដែលជះពីកសិដ្ឋានចិញ្ចឹមជ្រូក"**	តំណាងស្រុកកៀនស្វាយ និងបុគ្គលិកកម្មវិធី DAR

11:00 – 12:00	ការពិភាក្សា យោបល់ សំណួរ និងចម្លើយអំពីប្រធានបទខាងលើ	អ្នកចូលរួម
	សម្រាកពិសារអាហារថ្ងៃត្រង់	
01:30 – 01:45	ល្បែងថាមពល	អ្នកចូលរួម
01:45 – 2:45	**<u>កិច្ចពិភាក្សា (Panel Discussion) ស្តីពីមេរៀនបទពិសោធ</u>ន៍** ការអនុវត្តមុខងារគ្រប់គ្រងសម្រាមដែលបានផ្ទេរឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្រុងកំពត និងក្រុងបាត់ដំបង។ **"របៀបគ្រប់គ្រងសម្រាមនៅមូលដ្ឋាន"**	តំណាងក្រុងកំពត និងក្រុងបាត់ដំបង
2:45 – 3:00	**សម្រាកពិសារកាហ្វេ**	
3:00 – 4:00	ការពិភាក្សា យោបល់ សំណួរ និងចម្លើយអំពីប្រធានបទខាងលើ	អ្នកចូលរួម
4:00 – 5:00	**ការឆ្លុះបញ្ចាំង ៖** តើថ្ងៃនេះអ្នកចូលរួមបានរៀនសូត្រអ្វីខ្លះ? តើអ្វីដែលជម្រុញពួកគាត់សម្រាប់ការរៀនសូត្រនេះ? តើអ្វីដែលអ្នកចូលរួមចង់សាកល្បងអនុវត្តនៅពេលត្រឡប់ទៅក្រុងស្រុក និងក្រសួង ។ល។ របស់ខ្លួនវិញ? តើពួកគាត់ត្រូវការការគាំទ្រអ្វីខ្លះ ហើយពីនរណាខ្លះ?	អ្នកកាន់កម្មវិធី និងអ្នកចូលរួម
5:00 – 5:30	**ការកសាងក្រុម៖** លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមុខងារសាធារណ: ស្រុកដៃគូ និងកម្មវិធីDAR	អ្នកកាន់កម្មវិធី និងអ្នកចូលរួម
7:00 – 9:00	**ពិសារអាហារសាមគ្គីពេលល្ងាចរួមគ្នា**	អ្នកចូលរួម
២៨ កក្កដា ២០១៧		
8:00 – 8:30	រំលឹកឡើងវិញថ្ងៃទី១	
8:30 – 9:30	**<u>កិច្ចពិភាក្សា (Panel Discussion) ស្តីពីមេរៀនបទពិសោធ</u>ន៍** ការផ្តល់សេវាតាមរយៈការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ក្រុងស្រុក។ **"ការរៀនសូត្រអំពីប្រតិបត្តិការច្រកចេញចូលតែមួយនៅក្រុងបាត់ដំបង និងស្រុកមោងឫស្សី (រយៈពេល 6 ខែដំបូង) នៅខេត្តបាត់ដំបង ។**	តំណាងមកពីស្រុកមោងឫស្សី និងក្រុងបាត់ដំបង
9:30 – 10:00	ការពិភាក្សា យោបល់ សំណួរ និងចម្លើយអំពីប្រធានបទខាងលើ	អ្នកចូលរួម
10:00 – 10:15	**សម្រាកពិសារកាហ្វេ**	

10:15 – 10:45	**<u>បទបង្ហាញស្តីពីមេរៀនបទពិសោធ៖</u>** ការអភិវឌ្ឍសេដកិច្ចមូលដ្ឋានរបស់កម្មវិធី RED/GIZ	តំណាងកម្មវិធី RED
10:45 – 11:30	ការពិភាក្សា យោបល់ សំណួរ និងចម្លើយអំពីប្រធានបទខាងលើ	អ្នកចូលរួម
11:30 – 12:15	**ការឆ្លុះបញ្ចាំងក្រុមធំ ៖** តើអ្នកចូលរួមបានរៀនសូត្រអំពីអ្វីខ្លះ? តើមានអ្វីខ្លះដែលមានសារៈសំខាន់សម្រាប់ការងារថ្នាក់ជាតិ?តើមានអ្វីខ្លះដែលមានសារៈសំខាន់សម្រាប់ការងារថ្នាក់ក្រោមជាតិ? តើថ្នាក់ជាតិ (គ.ជ.អ.ប និងក្រសួងមុខងារសាធារណៈ) គួរគាំទ្រយ៉ាងដូចម្តេចដល់ក្រុមប្រឹក្សា និងរដ្ឋបាលថ្នាក់ក្រោមជាតិ?	អ្នកកាន់កម្មវិធី និងអ្នកចូលរួម
	សម្រាកអាហារថ្ងៃត្រង់	
01:30 – 01:45	ល្បែងថាមពល	អ្នកចូលរួម
01:45 – 03:00	**ពិភាក្សាលើទម្រង់/ឧបករណ៍ផ្សេងៗសម្រាប់ផ្លាស់ប្តូរ និងចែករំលែកមេរៀនបទពិសោធន៍ ៖** ការពង្រីក/ការផ្សព្វផ្សាយមេរៀនបទពិសោធដែលបានរៀនសូត្រទៅកាន់ក្រុងស្រុកផ្សេងទៀត និងការផ្លាស់ប្តូរ និងចែករំលែកគំនិតនៅទូទាំងប្រទេស។ បទបង្ហាញ និងការពិភាក្សាអំពីឧបករណ៍ផ្នែកព័ត៌មានសង្គម។	DAR អ្នកចូលរួម
03:00 – 03:15	**សម្រាកពិសារកាហ្វេ**	
03:15 – 03:30	បូកសរុបសម្រាប់រយៈពេលទាំងពីរថ្ងៃ ជំហ៊ានបន្ទាប់ និងការលាគ្នា	MC អ្នកចូលរួម
03:30 – 06:00	ធ្វើដំណើរត្រឡប់មកទីក្រុងភ្នំពេញវិញ	

DAR Learning Exchange Workshop
27 – 28 July 2017
Kep Province

---

1. Introduction

Public service delivery is the most crucial topic for sub-national administration since they are mandated to serve the citizens. Even though they are under the same regulatory environment, sub-national administrations (SNA) have different practices and approaches how to respond to the needs of the citizens. This is why exchanging practices and lessons (regardless whether they are good or bad) a) among SNA and b) between SNAs and the national level is important. This provides an opportunity for SNAs not only to exchange and learn how to respond to the needs of the citizens but it also provides an opportunity for national level to learn for their policy making about success and challenges in previous policy formulation. Based on these lessons and experiences the national level can adjust its policy debate and identify ways to successfully support SNAs.

To provide SNA and the national level space to exchange lessons and experiences, a first exchanging workshop will be organized by GIZ DAR and NCDD-S on **27 – 28 July 2017** in the **Rock Royal Hotel in Kep Province.** It will be the kick-off for a set of learning exchanges which will follow in the next 18 months.

2. Objective

Main objectives of the workshop are:

1) To learn and discuss how to coordinate/provide good services to citizens
2) To exchange good and challenging practices on how to respond to the needs of citizens,
3) To reflect policy implementation at the subnational level
4) To identify additional exchange formats which provide SNA the opportunity to regularly exchange lessons (social media)

3. Methodology:

Practices/stories related to public service delivery will be collected from districts and municipalities in both, DAR partner districts and selected districts/municipalities.

Before presenting those practices and experiences, NCDD-S and MCS will start with a short input on the roles and responsibilities of district councilors and SNA, the General Mandate of councils as well as on expectations from national level to subnational level. The importance of close coordination between different stakeholders from SNA and counciliors will be highlighted and subnational representatives encouraged to serve citizens through good service delivery.

In a second step, lessons learnt will be presented and shared by districts and municipalities. The case-based presentations and panel discussions will be developed based on guiding questions which help to structure the presentations. The presentations and panel discussions will provide an opportunity to reflect how to respond to the needs of the citizens, how to improve services to citizens and whom to coordinate with in order to deliver better services. All participants, especially those from SNAs, are encouraged to ask questions. The moderator will involve all participants from all levels into the panel and plenary discussions. This approach will allow all participants to make use of and take up experiences for their districts and ministries.

In the third step, NCDD-S and MCS will highlight their support to SNA. How does their support to district councilors and administration look like, what can they offer to the subnational level in terms of empowering SNA and councilors to deliver better services to citizens. Moreover, it will be discussed how national level can support subnational level in upscaling lessons learnt and experiences to other districts and how to bring together districts in order to learn from each other for better services delivery. GIZ DAR will present some tools for upscaling of lessons learnt and experience sharing and partners at national and subnational level are asked to decide about the utilization of these tools.

4. Agenda

Time	Topic	Responsibility
26 July 2017, all participants depart to Kep province		
27 July 2017		
08:30 – 09:00	Opening: Agenda and objective	MC
09:00 – 09:15	Introduction of Participants	MC, participants
09:15 – 09:45	Input on service delivery	NCDD-S/ MCS
09:45 – 10:00	Comments, Q & A	participants
10:00 – 10:15	**Coffee Break**	

10:15 – 11:00	Learning Example Presentation for the subnational level: Coordinated service delivery in the framework of the General Mandate in Kien Svay District, Kandal. Example: “how to handle the smell of a pig farm”.	Kien Svay representatives, DAR colleagues
11:00 – 12:00	Discussion, comments, Q&A on the Learning Example from Kien Svay	participants
Lunch Break		
01:30 – 01:45	Energizer	
01:45 – 02:45	Learning Example Panel Discussion from the subnational level: Transferred waste management functions to Kampot and Battambang Municipality. “How to locally manage solid waste”.	Kampot and Battambang Municipality representatives
02:45 – 03:00	**Coffee Break**	
03:00 – 04:00	Discussion, comments, Q&A on the Learning Example from Battambang and Kampot Municipality	Participants
04:00 – 05:00	Reflection Round: What did participants learn today? What inspired them? What would participants like to test back home in their districts, ministries etc.? What support do they need from whom?	MC, participants
05:00 – 05:30	Team Building NCDD-S, MCS, Partner Districts and DAR Program	DAR partners
07:00 – 09:00	Joint Dinner organized by DAR Program	participants
28 July 2017		
08:00 – 08:30	Review of Day 1	MC, participants
08:30 – 09:30	Learning Example Panel Discussion from the subnational level: Delivering services through One Window Service Offices at the District Level. “Learnings from the first six months in Moung Russei District, Battambang and from Battambang Municipality.”	Moung Russei and Battambang Municipality representatives
09:30 – 10:00	Discussion, comments, Q&A on the Learning Example from Battambang Province.	Participants
10:00 – 10:15	**Coffee Break**	

10:15 – 10:45	Learning Example Presentation from RED Program on Local Economic Development	Representatives?
10:45 – 11:30	Discussion, comments, Q&A on the Learning Example from RED.	Participants
11:30 – 12:15	Reflection Round in an open space: Learnings from the examples: What did participants learn? What is important for the work at the national level? What is important for the work at the subnational level? How can the national level (NCDD-S/MCS) support district councilors and SNA?	MC, participants
Lunch Break		
01:30 – 01:45	Energizer	Participants
01:45 – 03:00	Discussion on Exchange Formats: Upscaling lessons learnt to other districts and exchanging ideas country wide. Presentation and discussion on Social Media tools.	DAR, participants
03:00 – 03:15	**Coffee Break**	
03:00 – 03:30	Wrap up of the two days, next steps and farewell	MC, participants
03:30 – 06:00	Return to Phnom Penh	

Co-funded by the European Union

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

គជអប
NCDD

សិក្ខាសាលាផ្តាស់ប្តូរបទពិសោធន៍

២៧ និង២៨ ខែកក្កដា ឆ្នាំ២០១៧
នៅសណ្ឋាគារ រ៉ាក់ ឡូយ៉ាល់ ខេត្តកែប

គោលបំណង

- ពិភាក្សាអំពីវិធីសាស្ត្រសម្របសម្រួលដើម្បីផ្តល់សេវាឱ្យបានល្អដល់ប្រជាពលរដ្ឋ
- ផ្លាស់ប្តូរ និងចែករំលែកនូវបទពិសោធល្អ១ និងបញ្ហាប្រឈមនានាពាក់ព័ន្ធទៅនឹងការប្រតិបត្តិ/អនុវត្តក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ
- ឆ្លុះបញ្ចាំងអំពីការអនុវត្តន៍គោលនយោបាយនៅថ្នាក់ក្រោមជាតិ
- កំណត់ទម្រង់នានាសម្រាប់ផ្លាស់ប្តូរ និងចែករំលែកបទពិសោធន៍ដើម្បីផ្តល់ឱកាសឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបានចែករំលែក និងផ្លាស់ប្តូរបទពិសោធន៍នានាឱ្យបានទៀង

របៀបវារៈ

២៧ កក្កដា ២០១៧

- កម្មវិធីបើក
- ការណែនាំខ្លួន
- បទបង្ហាញស្តីពីតួនាទី ភារកិច្ច សិទ្ធអំណាច និងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដល់ប្រជាពលរដ្ឋ
- បទបង្ហាញរបស់ស្រុកកៀនស្វាយ
- កិច្ចពិភាក្សា ស្តីពីការអនុវត្តមុខងារគ្រប់គ្រងសម្រាមរបស់ខេត្តបាត់ដំបងនិងក្រុងកំពត
- សំណួរចម្លើយ

២៨ កក្កដា ២០១៧

- រំលឹកឡើងវិញ្ញ ២ ២ ២

Co-funded by the European Union

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

គជអប
NCDD

សិក្ខាសាលាចែករំលែកបទពិសោធន៍

ភ្ជាប់ការកិច្ច សិទ្ធអំណាច និងការផ្តល់សេវារបស់រដ្ឋចាលក្នុងកម្រិតជាតិជល់ប្រជាពលរដ្ឋ

រៀបចំដោយ៖ លេខាធិការដ្ឋាន ក.ជ.អ.ប និងក្រសួងមុខងារសាធារណៈ

ខេត្ត កែប

២៧ – ២៨ កក្កដា ២០១៧

គណនេយ្យភាព សិទ្ធអំណាច តួនាទី និងការកិច្ចរបស់ក្រុមប្រឹក្សា

- ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះ៖
  - ✓ ប្រជាពលរដ្ឋ – ឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ
  - ✓ រាជរដ្ឋាភិបាល – អនុលោមតាមក្របខ្ណឌច្បាប់របស់រាជរដ្ឋាភិបាល
  - ✓ គណនេយ្យភាពផ្ទៃក្នុង (រវាងគណៈអភិបាល រដ្ឋបាល និងក្រុមប្រឹក្សា)
- ក្រុមប្រឹក្សាមានសិទ្ធអំណាចធ្វើសេចក្តីសម្រេចចិត្តខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ៖
  - ✓ ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធអំណាចខាងបញ្ញត្តិតាមរយៈការចេញដីកា និង
  - ✓ សិទ្ធអំណាចខាងប្រតិបត្តិតាមរយៈការធ្វើសេចក្តីសម្រេច
- ក្រុមប្រឹក្សាត្រូវអនុវត្តមុខងារដូចខាងក្រោម ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ៖
  - ✓ មុខងារជាកតព្វកិច្ច (តាមរយៈការផ្ទេរមុខងារ និងប្រតិភូកម្ម) និង
  - ✓ មុខងារជាជម្រើស

តើរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើដូចម្តេចដើម្បីផ្តល់សេវាឲ្យបានល្អដល់ប្រជាពលរដ្ឋ?

- SNA យល់ដឹងអំពីខ្សែគណនេយ្យភាព សិទ្ធអំណាច តួនាទី និងការកិច្ចរបស់ខ្លួន
- SNA យល់ពីតម្រូវការប្រជាពលរដ្ឋ
- SNA ធ្វើសេចក្តីសម្រេចចិត្តអំពីបញ្ហា/តម្រូវការលើកឡើងដោយប្រជាពលរដ្ឋ៖ ការព្រមព្រៀងគ្នាក្នុងចំណោមសមាជិកក្រុមប្រឹក្សា និងការព្រមព្រៀងលើសកម្មភាពអនុវត្ត
- SNA អនុវត្តសេចក្តីសម្រេចដោយប្រសិទ្ធភាព (ការរៀបចំផែនការអនុវត្ត ការគ្រប់គ្រង ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ)
- SNA សម្របសម្រួលជាមួយអ្នកពាក់ព័ន្ធ ដូចជា៖ ការិយាល័យជំនាញ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ដើម្បីកៀងគរធនធាន និងសម្របសម្រួលដំណើរការផ្តល់សេវា)
- SNA កសាងទំនាក់ទំនងផ្ទៃក្នុង និងអន្តររដ្ឋបាល ដើម្បីចែករំលែក ព័ត៌មាន សម្របសម្រួល និងសហការ

តើរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើដូចម្តេច.....?(បន្ត)

- SNA អនុវត្តឧបករណ៍គ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស (ដូចជាការពិព័ណ៌នាមុខតំណែង ប្រព័ន្ធគ្រប់គ្រងគុណផល ការលើកទឹកចិត្ត ការអភិវឌ្ឍសមត្ថភាព និងបណ្តុះបណ្តាលផ្តោតលើការផ្លាស់ប្តូរតួនាទី (ជាអ្នកផ្តល់សេវា) ការអភិវឌ្ឍជំនាញ និងភាពជាអ្នកដឹកនាំ...
- SNA អនុវត្តយន្តការធានាគុណភាពសេវា (តួនាទីច្បាស់លាស់ក្នុងការងារតាមដាន ការចូលរួមរបស់ប្រជាពលរដ្ឋ ការរៀបចំស្តង់ដារសេវា និងការអនុវត្តយន្តការផ្តល់យោបល់ត្រលប់)
- SNA មានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ (មូលនិធិក្រុងស្រុក ចំណូលមូលដ្ឋាន និងធនធានផ្សេងទៀត)
- SNA ទទួលបានការគាំទ្រជាប្រចាំពីថ្នាក់ជាតិ
- SNA ផ្លាស់ប្តូរបទពិសោធជាប្រចាំជាមួយ SNA ផ្សេងៗទៀត និងជាមួយអ្នករៀបចំគោលនយោបាយថ្នាក់ជាតិ ហើយធ្វើការឆ្លុះបញ្ចាំងជាប្រចាំអំពីអ្វីដែលធ្វើបានល្អ និងអ្វីដែលមិនទាន់បានល្អ ។

តើរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធណាខ្លះ?



Co-funded by the European Union

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

គជអប
NCDD

សូមអរគុណ

Co-funded by the European Union

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

គជអប NCDD

បទបង្ហាញស្តីពី ផលបះពាល់ដល់ដំណាក់ស្រទាបសហគមន៍ប្រជាពលរដ្ឋដោយសារការបង្ហូរកាកសំណល់រាចម៉ាជ្រុក និងក្លិនស្អុយពីកសិដ្ឋានចិញ្ចឹមជ្រូក

នៅឃុំកំពង់ស្វាយ ស្រុក ក្បៀនស្វាយ ខេត្ត កណ្តាល

បង្ហាញដោយ៖ លោកញ៉ូប ប៊ុនតិច (សមាជិកក្រុមប្រឹក្សា)

Co-funded by the European Union

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

គជអប NCDD

ខ្លឹមសារនៃបទបង្ហាញ

១. ប្រវត្តិបញ្ហា

២. ដំណើរការដោះស្រាយបញ្ហា

៣. កិច្ចសហការជាមួយអ្នកពាក់ព័ន្ធផ្សេងៗ

៤. លទ្ធផលនៃការអនុវត្ត

៥. បញ្ហាប្រឈមក្នុងការដោះស្រាយបញ្ហា

៦. ត្រូវការកាគាំទ្រពីថ្នាក់ខេត្ត និង ការិយាល័យ

៧. ផែនការរបស់ក្រុមការងារ

Co-funded by the European Union

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

គជអប NCDD

១. ប្រវត្តិបញ្ហា

- ប្រជាពលរដ្ឋបានលើកឡើងពីការបង្ហូរកាកសំណល់ចូលស្រែរបស់ប្រជាពលរដ្ឋដែលធ្វើឱ្យខូចស្រូវ និងមានក្លិនស្អុយពីកសិដ្ឋានចិញ្ចឹមជ្រូក
- បញ្ហានេះលើកឡើងតាមរយៈក្រុមប្រឹក្សាដែលទទួលខុសត្រូវនៅក្នុងឃុំ

២. ដំណើរការដោះស្រាយបញ្ហា

ក្រុមប្រឹក្សាជួបជុំដើម្បីពិភាក្សារកដំណោះស្រាយ

↓

ក្រុមប្រឹក្សាដាក់បញ្ហាចូលក្នុងកិច្ចប្រជុំដើម្បីពិភាក្សានិងអនុម័ត

↓

គណៈអភិបាលបានសម្រេចបង្កើតក្រុមការងារទទួលខុសត្រូវដើម្បីដោះស្រាយបញ្ហា

↓

ក្រុមការងារចុះជួបជាមួយម្ចាស់កសិដ្ឋាន

- ម្ចាស់កសិដ្ឋានត្រូវមានកាតព្វកិច្ចមួយចំនួនដូចខាងក្រោម៖
  - ❖ ចុះកិច្ចសន្យាជាមួយមន្ទីរបរិដ្ឋានដើម្បីធានាថារក្សាបរិដ្ឋានអោយបានស្អាត
  - ❖ ទទួលយកការផ្តល់បច្ចេកទេសពីខាងការិយាល័យកសិកម្មក្នុងការបំបាត់ក្លិនស្អុយ
  - ❖ ស្តាប្រឡាយដែលផ្ទុកកាកសំណល់ចង្ហាន់ទឹកនាំអោយខូចស្រូវប្រជាពលរដ្ឋ

ក្រុមការងារ៖ អភិបាលរងទទួលបន្ទុកម្នាក់
ប្រធានការិយាល័យបរិដ្ឋាន
ប្រធានការិយាល័យកសិកម្មនិងពេទ្យសត្ត

Co-funded by the European Union

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

គជអប NCDD

៣. កិច្ចសហការជាមួយអ្នកពាក់ព័ន្ធផ្សេងៗ

- ការិយាល័យបរិដ្ឋាន (មានតួនាទីពិនិត្យ និងរាយការណ៍ជូនខ្សែបណ្តាយរបស់គាត់)
- ការិយាល័យកសិកម្ម និងពេទ្យសត្ត (រាយការណ៍ជូនខ្សែបណ្តាយរបស់គាត់និងផ្តល់បច្ចេកទេសដល់ប្រជាពលរដ្ឋដែលដំណាំស្រូវរបស់ពួកគាត់រងផលប៉ះពាល់)
- មេឃុំ និងមេភូមិ (សម្របសម្រួល និងជូនដំណឹងដល់ម្ចាស់កសិដ្ឋាន)

Co-funded by the European Union

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für internationale Zusammenarbeit (GIZ) GmbH

NCDD

៤. លទ្ធផលនៃការអនុវត្ត

- មន្ទីរបរិដ្ឋានខេត្តនិងការិយាល័យស្រុកបានចុះពិនិត្យដល់កសិដ្ឋានចិញ្ចឹមជ្រូក
- មន្ទីរបរិដ្ឋានសូមឱ្យម្ចាស់កសិដ្ឋានចុះកិច្ចសន្យាក្នុងការថែរក្សាបរិដ្ឋានឱ្យបានស្អាត

Co-funded by the European Union

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

NCDD

៥. បញ្ហាប្រឈមក្នុងការដោះស្រាយបញ្ហា

- ម្ចាស់កសិដ្ឋានមិនសូវយកចិត្តទុកដាក់ពីការផ្តល់យោបល់របស់ការិយាល័យជំនាញដោយសារជ្រូករបស់គាត់ធ្លាក់ថ្លៃ
- ក្រុមការងារដែលទទួលបន្ទុកខ្វះការតាមដាន
- មានការរវល់ច្រើននិងការរៀបចំបោះឆ្នោតឃុំ សង្កាត់
- មានការពន្យាពេលពីថ្នាក់ខេត្តដោយសារជាប់រវល់មិនបានចុះទៅធ្វើកិច្ចសន្យាភ្លាម១ជាមួយម្ចាស់កសិដ្ឋានទោះមានការជូនដំណឹងពីការិយាល័យបរិដ្ឋានស្រុក

Co-funded by the European Union
កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT
អនុវត្តដោយ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH
គជអប NCDD

៦. ត្រួតការពិនិត្យពីថ្នាក់ខេត្ត ការិយាល័យនិងអ្នកពាក់ព័ន្ធនានា

- សូមឱ្យថ្នាក់ខេត្ត (មន្ទីរពាក់ព័ន្ធនានា)ជួយធ្វើអន្តរគមន៍ឱ្យបានលឿនបន្ទាប់ពីទទួលព័ត៌មានពីការិយាល័យជំនាញនានា
- ការិយាល័យជំនាញបន្តការសហការណ៍
- ការិយាល័យជំនាញគួររៀបចំផែនការតាមដានត្រួតពិនិត្យអោយបានទៀតទាត់ជាមួយម្ចាស់កសិដ្ឋានហើយរាយការណ៍អោយទាន់ពេលវេលាជូនក្រុមប្រឹក្សា
- សូមឱ្យមានជាលិខិតបញ្ជូនបេសកម្មដើម្បីចុះធ្វើសកម្មភាព

Co-funded by the European Union

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für internationale Zusammenarbeit (GIZ) GmbH

គជអប NCDD

៧. ផែនការបន្តរបស់ក្រុមប្រឹក្សា

- តាមដានការអនុវត្តរបស់គណៈអភិបាលដើម្បីជំរុញការអនុវត្តឱ្យបានលឿនតាមរយៈកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
- តាមដានជាប្រចាំជាមួយក្រុមការងាររបស់ក្រុមប្រឹក្សាដែលទទួលខុសត្រូវក្នុងឃុំកំពង់ស្វាយដើម្បីដឹងពីព័ត៌មានទាក់ទងនិងកសិដ្ឋានចិញ្ចឹមជ្រូកនោះ

Co-funded by the European Union

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für internationale Zusammenarbeit (GIZ) GmbH

គជអប
NCDD

សូមអរគុណក្នុងការយកចិត្តទុកដាក់ស្តាប់

ករណីសិក្សាអំពីកសិដ្ឋានចិញ្ចឹមជ្រូក ស្រុកកៀនស្វាយ

បន្ទាប់ពីលោក លោកស្រីបានស្តាប់បទបង្ហាញស្តីអំពីបញ្ហាកសិដ្ឋានចិញ្ចឹមជ្រូករបស់ស្រុកកៀនស្វាយរួច ។ ប្រសិនបើករណីនេះកើតមានឡើងក្នុងស្រុករបស់លោក លោកស្រី តើលោកលោកស្រីមានចំណុចគន្លឹះសំខាន់ៗអ្វីខ្លះបន្ថែមទៀតដើម្បីដោះស្រាយបញ្ហានេះឱ្យកាន់តែប្រសើរឡើង?

Co-funded by the European Union

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

គជអប NCDD

សំណួរឆ្លុះបញ្ចាំងសម្រាប់ថ្ងៃទី០១

(កសិដ្ឋានចិញ្ចឹមជ្រូក និងការគ្រប់គ្រងសំរាម ក្រុងបាត់ដំបង និងកំពត)

- តើលោក លោកស្រីបានរៀនសូត្រអ្វីខ្លះសម្រាប់ថ្ងៃនេះ?
- តើមានកត្តាអ្វីខ្លះដែលជម្រុញឱ្យពួកគាត់លើកយកការងារនេះមកដោះស្រាយ?
- តើលោក លោកស្រីនឹងយកចំណុចណាខ្លះ ដែលរៀនសូត្របានពីថ្ងៃនេះទៅអនុវត្តសាកល្បងនៅកន្លែងការងារវិញ?
- តើលោក លោកស្រីត្រូវការការគាំទ្រអ្វីខ្លះទៀត? ហើយចង់បានការគាំទ្រពីអ្នកណាដែរ?

ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្រុងបាត់ដំបង

១. ប្រវត្តិនៃបញ្ហា

សំរាម សំណល់រឹងត្រូវបានគេបោះចោលជារៀងរាល់ថ្ងៃនៅតាមដងផ្លូវ ប្រឡាយទឹក និងទីធ្លាសាធារណៈទាំងនៅតាមតំបន់ជនបទ និងនៅតាមទីក្រុង ដោយសារប្រជាពលរដ្ឋមិនបានយល់ដឹងអំពីផលប៉ះពាល់ជាអវិជ្ជមានដល់សុខភាពមនុស្ស សត្ត និងរុក្ខជាតិ រួមផ្សំនឹងការផ្សព្វផ្សាយអប់រំមិនទាន់បានទូលំទូលាយ និងការអនុវត្តច្បាប់មិនទាន់បានពង្រឹង។ ការគ្រប់គ្រងកាកសំណល់ទីក្រុងតម្រូវឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធដូចជា៖ ប្រជាពលរដ្ឋ ក្រុមហ៊ុនម៉ៅការដឹកជញ្ជូននិងប្រមូលសំរាម សំណល់រឹង និងរដ្ឋអំណាចមូលដ្ឋាន ដែលជាកត្តាដ៏មានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងសំណល់ទីក្រុង ដែលចេះតែមានចំនួនកាន់តែកើនឡើង។ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ ១១៣អនក្រ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ក៏ប៉ុន្តែអនុក្រឹត្យនេះនៅមានលក្ខណៈទូលំទូលាយសម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ហើយតួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធក៏មិនទាន់បានកំណត់ឲ្យបានច្បាស់លាស់នៅឡើយដែរ។ ដូចនេះ រដ្ឋបាលក្រុងចាំបាច់ត្រូវបង្កើតក្រុមការងារគ្រប់គ្រងសំរាម សំណល់រឹងទីក្រុងដែលមានសមត្ថកិច្ចគ្រប់គ្រាន់ និងរៀចចំឲ្យមានដីការបស់ក្រុមប្រឹក្សា ដែលជាគោលនយោបាយនៅមូលដ្ឋានសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងដើម្បីដាក់ឲ្យគណៈអភិបាលរបស់ខ្លួនអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុងបាត់ដំបង។

ប្រជាពលរដ្ឋមួយភាគនៃក្រុងបាត់ដំបងមិនទាន់បានប្រើប្រាស់សេវាប្រមូលសំរាម សំណល់រឹងនៅឡើយទេ។ កត្តានេះហើយនៅតែមានសំរាម សំណង់រឹងត្រូវបានគេបោះចោលនៅតាមដងផ្លូវ ទីសាធារណៈ ខណៈប្រជាពលរដ្ឋខ្លះទៀតបានធ្វើការតួញតែ្ពរចំពោះការប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងរបស់ក្រុមហ៊ុនម៉ៅការ ដែលអនុវត្តការងាររបស់ខ្លួនមិនទាន់បានរលូនល្អ។ ការចូលរួមរបស់ភាគីពាក់ព័ន្ធនានា ជាពិសេសអាជ្ញាធរសង្កាត់ ភូមិមិនទាន់បានចូលរួមគ្រប់គ្រងសំរាម សំណល់រឹងទីក្រុងនៅក្នុងមូលដ្ឋានរបស់ខ្លួនបានសកម្មនៅឡើយ។ បន្ថែមលើសនេះទៀត យន្តការអនុវត្តការផាកពិន័យចំពោះបទល្មើសបោះចោលសំរាម សំណល់រឹងផ្តេសផ្តាស នៅមានភាពមិនច្បាស់លាស់នៅឡើយដែរ។

កន្លងមកការិយាល័យសោភ័ណភាព និងគ្រប់គ្រងកាកសំណល់ក្រុងបានរាយការណ៍ជូនក្រុមប្រឹក្សាក្រុងអំពីផលលំបាកនានាទាក់ទងនឹងការគ្រប់គ្រងសំរាម សំណល់រឹងក្នុងទីក្រុង។ ទន្ទឹមនឹងនេះ ក៏មានការលើកឡើងផងដែរអំពីប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងដោយសមាជិកក្រុមប្រឹក្សាក្រុង។

២. ដំណើរការដោះស្រាយបញ្ហា

ការិយាល័យសោភ័ណភាពក្រុង ដោយមានកិច្ចសហការជាមួយការិយាល័យបរិស្ថាន បានចុះធ្វើការសិក្សាពីប្រសិទ្ធភាពនៃការប្រមូលសំរាម សំណល់រឹង និងបានរាយការណ៍ជូនគណៈអភិបាល ហើយគណៈអភិបាលបានរាយការណ៍នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ ក្រុមប្រឹក្សាបានពិភាក្សា និងបានដាក់ចេញនូវសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងសំរាម សំណល់រឹងទីក្រុង នៅក្នុងកិច្ចប្រជុំសាមញ្ញរបស់ខ្លួន។ សេចក្តីសម្រេចនេះបានកត់

ត្រាទុកនៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ហើយថ្មីនេះរដ្ឋបាលក្រុងបានធ្វើពង្រាងដីកាក្រុមប្រឹក្សាសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងក្នុងទីប្រជុំជនក្រុងដែរ។

ការិយាល័យសោភ័ណភាព និងគ្រប់គ្រងកាកសំណង់ក្រុងបានសហការជាមួយក្រុមប្រឹក្សាសង្កាត់ មេភូមិ និងការិយាល័យបរិស្ថាន ព្រមទាំងជាមួយអង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា (COMPED)។ កិច្ចសហការជាមួយក្រុមប្រឹក្សាសង្កាត់គឺ បានធ្វើសកម្មភាពអប់រំផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋចូលរួមប្រើប្រាស់សេវាប្រមូលសំរាម។ លើសពីនេះទៅទៀត ក្រុមការងារគ្រប់គ្រងសំរាម សំណល់រឹងទីក្រុងក៏មានសមាជិកជាតំណាងក្រុមប្រឹក្សាសង្កាត់ដែលទទួលបន្ទុកការងារអនាម័យ បរិស្ថានតាមសង្កាត់និមួយៗផងដែរ។ការិយាល័យសោភ័ណភាព និងគ្រប់គ្រងកាកសំណង់ក្រុងក៏បានសហការ និងបានពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់ក្នុងក្រុងដើម្បីរៀបចំតាក់តែងដីការបស់ក្រុមប្រឹក្សា និងស្នើសុំអនុលោមភាពលើដីកាពីរដ្ឋបាលខេត្ត ក្រុមប្រឹក្សាខេត្ត។

ការិយាល័យសោភ័ណភាព និងគ្រប់គ្រងកាកសំណង់ក្រុងបានប្រើប្រាស់ថវិកាសេវាអនាម័យបរិស្ថានជាប្រាក់វិភាជន៍ពីរាជរដ្ឋាភិបាលតាមរយៈក្រសួងក្រសួងបរិស្ថាន។ រដ្ឋបាលក្រុងមិនមានថវិកា ដែលជាចំណែកមួយនៃថវិកាក្រុងស្រុកសម្រាប់ការចំណាយលើការងារនេះទេ។

<u>ការងារគ្រប់គ្រងធនធានមនុស្សនិងប្រព័ន្ធគ្រប់គ្រងគុណផល</u>

ការិយាល័យសោភ័ណភាពក្រុង មានបុគ្គលិកបំពេញការងារចំនួន ៥នាក់។ ការគ្រប់គ្រងបុគ្គលិកនៅមានភាពធូរលុង ជាហេតុធ្វើឲ្យមន្ត្រីមួយចំនួនហាក់ដូចជាមិនសូវមានឆន្ទៈក្នុងការបំពេញការងារ។ មន្ត្រីទាំងអស់ត្រូវឆ្លងកាត់ការវាយតម្លៃការបំពេញការងារនៅរៀងរាល់៣ខែម្តង ដើម្បីទទួលបានការបែងចែកប្រាក់ចំណូល ដែលបានពីការិយាល័យ ច្រកចេញចូលតែមួយ។ មន្ត្រីមួយចំនួនបានទទួលការបណ្តុះបណ្តាលដើម្បីបង្កើនសមត្ថភាព ដូចជា ផ្តល់ការបណ្តុះបណ្តាលនៅប្រទេសជប៉ុនរយៈពេល ៣ខែ ទស្សនកិច្ចសិក្សានៅប្រទេសថៃ និងនៅប្រទេសហ្វីលីពីន។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ សមត្ថភាពជំនាញរបស់មន្ត្រីទាក់ទិននឹងការងារគ្រប់គ្រងកាកសំណល់នៅមានកម្រិតនៅឡើយ។

<u>ការតាមដាននិងត្រួតពិនិត្យ</u>

ក្រុមប្រឹក្សាបានចេញសេចក្តីសម្រេចបង្កើតក្រុមការងារ ហើយបានកំណត់អំពីការទទួលខុសត្រូវ ការបែងចែកតួនាទី ភារកិច្ចច្បាស់លាស់។ បន្ថែមលើសពីនោះទៀត តំណាងក្រុមប្រឹក្សាសង្កាត់ត្រូវរាយការណ៍មកការិយាល័យសោភ័ណភាពក្រុងអំពីហេតុការណ៍ដែលកើតឡើងពាក់ព័ន្ធនឹងសំរាម សំណល់រឹង។ ការិយាល័យសោភ័ណភាពក្រុងត្រួតពិនិត្យ និងវាយតម្លៃរបាយការណ៍របស់ក្រុមការងារគ្រប់គ្រងសំរាម សំណល់រឹងទីក្រុង ដែលបានដាក់ជូនរដ្ឋបាលក្រុង។ ការិយាល័យចាត់តាំងឲ្យមន្ត្រីចំនួន៣នាក់ ចុះតាមមូលដ្ឋានប្រចាំថ្ងៃ។ បន្ថែមលើសពីនោះទៅទៀត មានការលើកទឹកចិត្តឲ្យប្រជាពលរដ្ឋចូលរួមសកម្មក្នុងការត្រួតពិនិត្យ និងរាយការណ៍មកការិយាល័យសោភ័ណភាពក្រុង តាមរយៈប្រអប់គណនេយ្យភាព (ការិយាល័យពលរដ្ឋជាអ្នកបើកប្រអប់) និងជួបផ្ទាល់ជាមួយមន្ត្រីការិយាល័យសោភ័ណភាពក្រុង និងរាយការណ៍នៅតាមសង្កាត់ ដើម្បីមានវិធានការដោះស្រាយ។ តាមរយៈកម្មវិធីពន្លឺមូលដ្ឋាន (វិទ្យុផ្សាយសំលេងក្នុងខេត្ត) ប្រជាពលរដ្ឋក៏អាចផ្តល់ជាសំណូមពរ ផ្តល់យោបល់អំពីសំរាម សំណល់រឹងបាន ដូចជា ស្នើឲ្យដាក់

ធុងសំរាមបន្ថែមតាមទីធ្លាសាធារណៈដោយពួកគាត់ចាប់ផ្តើមមានការចាប់អារម្មណ៍ចំពោះសំរាម និងផលលំបាករបស់វាដែលធ្វើឲ្យប៉ះពាល់ដល់ការរស់នៅរបស់គាត់។

៣. បញ្ហាប្រឈមនានា

- ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីបញ្ហាសំរាម សំណល់រឹងនៅមានកម្រិតទាប ទាំងការបែងចែក ការវេចខ្ចប់ និងការទុកដាក់សំរាម។
- ប្រជាពលរដ្ឋមួយចំនួនមិនទាន់បានចូលរួមប្រើប្រាស់សេវាប្រមូលសំរាម និងបង់ថ្លៃសេវាប្រមូលសំរាម។
- ប្រសិទ្ធភាពនៃការអនុវត្តកិច្ចសន្យារបស់ក្រុមហ៊ុនម៉ៅការដឹកជញ្ជូន និងប្រមូលសំរាមនៅមានកម្រិត និងខ្វះជំនាញក្នុងរៀបចំផែនការប្រមូលសំរាម។
- សិទ្ធអំណាចរបស់រដ្ឋបាលក្រុង និងការិយាល័យទទួលបន្ទុកនៅមានភាពមិនច្បាស់លាស់ក្នុងការតាមដាន ត្រួតពិនិត្យការអនុវត្តកិច្ចសន្យារបស់ក្រុមហ៊ុន (កិច្ចសន្យាចាស់)។

ទន្ទឹមនឹងបញ្ហាប្រឈមនេះ រដ្ឋបាលក្រុងបានទទួលការគាំទ្រពីថ្នាក់ខេត្ត ថ្នាក់ជាតិ ក្នុងការដោះស្រាយបញ្ហា ដូចជា ពីថ្នាក់ជាតិ គឺរាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ ១៣៣ អនក្រ ស្តីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន បានផ្តល់ថវិកាសម្រាប់ការអនុវត្តគម្រោងសេវាអនាម័យបរិស្ថានសំណល់រឹងរាវដល់រដ្ឋបាលក្រុង។ចំណែកឯរដ្ឋបាលខេត្តបានយកចិត្តទុកដាក់ និងលើកទឹកចិត្តជម្រុញការងារគ្រប់គ្រងសំរាម សំណល់រឹង។ ជាក់ស្តែងឯកឧត្តមអភិបាលនៃគណៈអភិបាលបានចូលរួមជាប្រចាំរាល់សកម្មភាពអនាម័យបរិស្ថាន ហើយតែងតែណែនាំឲ្យរដ្ឋបាលក្រុងគិតគូដល់ការជាកពិន័យចំពោះសកម្មភាពល្មើស ដែលជាវិធានការមួយដើម្បីកាត់បន្ថយការបោសំរាមចោលពាសវាលពាសកាល។ ទន្ទឹមនឹងការគាំទ្រខាងលើនេះ រដ្ឋបាលខេត្តនៅជួបប្រទះនូវបញ្ហាមន្ត្រី ដែលជាបញ្ហាសំខាន់មួយក្នុងចំណោមបញ្ហាសំខាន់ៗជាច្រើន ដូចនេះរដ្ឋបាលក្រុងសូមស្នើផ្តល់មន្ត្រីឲ្យមកបំពេញការងារក្នុងការិយាល័យសោភ័ណភាព និងគ្រប់គ្រងកាកសំណល់រឹងក្រុងបន្ថែមទៀត ដើម្បីឆ្លើយតបនឹងទំហំការងារនិងតម្រូវការនាពេលបច្ចុប្បន្ន។ ការផ្ទេរមុខងារលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនមករដ្ឋបាលក្រុងក៏ត្រូវមានលក្ខណៈច្បាស់លាស់ អមដោយថវិកាបន្ថែមសម្រាប់សេវាកម្មអនាម័យបរិស្ថាននេះផងដែរ។

៤. ការចែករំលែកបទពិសោធន៍

នៅក្នុងប្រទេសកម្ពុជា រដ្ឋបាលក្រុងបានចូលរួមចែករំលែកបទពិសោធន៍ជាមួយរដ្ឋបាលក្រុង ស្រុកផ្សេងៗដូចជាបានធ្វើបទបង្ហាញនៅភ្នំពេញ ក្នុងអំឡុងខែតុលា ឆ្នាំ២០១៦ ក្នុងឱកាសនោះមានតំណាងមកពីគ្រប់ក្រុងស្រុកបានចូលរួម។ កម្មវិធីចែករំលែកបទពិសោធន៍បានទទួលការឧបត្ថម្ភពីមូលនិធិខុនរ៉ាដអាឌិនណៅអ៊ែរ សហការជាមួយសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន (NLC)។ ការចែករំលែកបទពិសោធន៍កន្លងមកមានដូចជា តាមរយៈសិក្ខាសាលានិងកិច្ចប្រជុំពិគ្រោះយោបល់ជូនអង្គការពាក់ព័ន្ធ នៅក្នុង និងក្រៅប្រទេស ដូចជា៖ អង្គការ CCAC (Climate and Clean Air Coalition) នៅអ៊ីតាលីក្នុងឆ្នាំ២០១៣, នៅទីក្រុងប៉ារីសក្នុងឆ្នាំ ២០១៥, ប្រទេសម៉ាឌីវ, ប្រទេសប្រេស៊ីលអំពីការលើកកម្ពស់ 3R (Recycle, Reuse, and Reduce (2015)), Australia (2016), Institute for Global

Environmental Strategy (IGES) នៅជប៉ុន (២០១៣) នៅទីក្រុងពិស្នុកលោកនៃប្រទេសថៃ និងនៅទីក្រុងប៉ូណាំងនៃប្រទេសម៉ាឡេស៊ី។

ភាពជោគជ័យរបស់រដ្ឋបាលក្រុង គឺការកែច្នៃសំណល់ និងប្រើប្រាស់សំណល់ (ធ្វើជី និងការប្រើប្រាស់ដបឡើងវិញ) ក៏ប៉ុន្តែការខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយការប្រើប្រាស់ (Reduce) ជួបប្រទះនូវបញ្ហាប្រឈមដោយបញ្ហាសំរាមចេះតែកើនឡើង។ ការិយាល័យសោភ័ណភាពក្រុងស្នើឲ្យមានបណ្តាញក្រុង ស្រុក ដែលទទួលបន្ទុកការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដើម្បីបានចែករំលែកបទពិសោធន៍ និងមេរៀនល្អៗ និងចូលរួមដោះស្រាយរួមគ្នា។ សូមបន្តឲ្យមានការធ្វើទស្សនកិច្ចសិក្សានៅក្នុងប្រទេស និងក្រៅប្រទេសបន្ថែមទៀត ដើម្បីរៀនសូត្រដកស្រង់បទពិសោធន៍ថ្មីៗ រួមនឹងការផ្តល់ការបណ្តុះបណ្តាលបន្ថែមដល់មន្ត្រី។ ការិយាល័យសោភ័ណភាពក្រុង សូមស្នើសុំឲ្យមានការណែនាំ និងបង្កើតយន្តការនានា ដើម្បីអនុវត្តការជាកពិន័យចំពោះជនល្មើស និងយន្តការទទួលព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋ និងពីភាគីពាក់ព័ន្ធក៏ ដែលជាកត្តាសំខាន់ក្នុងការងារគ្រប់គ្រងសំរាម សំណល់រឹង។

****

ការិយាល័យច្រកចេញចូលតែមួយក្រុងបាត់ដំបង

១. សាវតា

ស្រុកបាត់ដំបង និងស្រុកសៀមរាប ដែលបច្ចុប្បន្នបានប្រែក្លាយជាក្រុងបាត់ដំបង និងក្រុងសៀមរាប ត្រូវបានជ្រើសរើសដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីអនុវត្តគម្រោងសាកល្បងស្តីពីកំណែទម្រង់រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលស្រុកតាមរយៈការដាក់ចេញនូវសេចក្តីសម្រេចលេខ ៤៧សសរ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៣ ។ នៅក្នុងក្របខ័ណ្ឌនៃគម្រោងសាកល្បងនេះ រដ្ឋបាលក្រុងទាំងពីរបានបង្កើតឲ្យមានការិយាល័យច្រកចេញចូលតែមួយ តាមរយៈប្រកាសលេខ ៧៩២ ប្រក របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីការរៀបចំ និងការព្រឹត្តិទៅនៃការិយាល័យច្រកចេញចូលតែមួយ នៅស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង សម្រាប់ជាកន្លែងផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ សហគ្រិន ក្រុមហ៊ុន អាជីវកម្ម-សេវាកម្ម ពាណិជ្ជករ សិស្ស និស្សិត និងប្រជាពលរដ្ឋគ្រប់ស្រទាប់ ប្រកបដោយតម្លាភាព ប្រសិទ្ធិភាព ប្រសិទ្ធិផល ដែលជាគំរូនៃអភិបាលកិច្ចល្អ។ ការិយាល័យច្រកចេញចូលតែមួយត្រូវបានប្រកាសជាផ្លូវការថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេច ក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នៅឆ្នាំ២០១៣មានក្រសួងចំនួន០២បានធ្វើប្រភិភូកម្មបន្ថែម ហើយនៅឆ្នាំ២០១៤ មានក្រសួងចំនួន០១ បានធ្វើប្រភិភូកម្មបន្ថែម និងអត្រានុកូលដ្ឋានបានប្រគល់មកឲ្យរដ្ឋបាលក្រុងផងដែរ និងឆ្នាំ២០១៥ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានធ្វើប្រភិភូកម្មការងារសុរិយោដីបន្ថែមទៀត ដែលរហូតមកដល់បច្ចុប្បន្ននេះ ការិយាល័យច្រកចេញចូលតែមួយបាននិងកំពុងអនុវត្តការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋមាន១២សេវាលើវិស័យ ។

២. ដំណើរការ

- **ការផ្សព្វផ្សាយ និងការបញ្ជ្រាបការយល់ដឹង៖**

នៅពេលដាក់ឲ្យដំណើរការជាផ្លូវការរដ្ឋបាលក្រុងបានធ្វើយុទ្ធនាការផ្សព្វផ្សាយតាមរយៈការហែក្ឆួនរថយន្ត ម៉ូតូដោយមានចងបដា និងទងរបស់ការិយាល័យច្រកចេញចូលតែមួយ និងមានការចូលរួមពីសំណាក់ ប្រជាពលរដ្ឋ សិស្ស និស្សិត មន្ត្រីរាជការ នៅតាមដងផ្លូវទូទាំងក្រុង និងមានការចែកខិតប័ណ្ណ ចុះផ្សព្វផ្សាយប្រជាពលរដ្ឋតាមសង្កាត់ទាំង១០នៃក្រុងបន្ថែម ។ ក្រៅពីនោះក៏នៅមានការផ្សព្វផ្សាយជាប្រចាំ តាមរយៈការប្រជុំផ្សេងៗរបស់ គណៈអភិបាលជាមួយស្ថាបនផ្សេងៗ កិច្ចប្រជុំក្រុមប្រឹក្សាប្រចាំខែ វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាលើគ្រប់វិស័យរបស់រដ្ឋបាលក្រុងប្រចាំឆមាស ឆ្នាំ វេទិការសាធារណៈរបស់ការិយាល័យច្រកចេញចូលតែមួយ ការផ្សព្វផ្សាយតាម កាសែត វិទ្យុ ទូរទស្សន៍ ការចូលរួមធ្វើជាវាគ្មិនតាមវិទ្យុ ការធ្វើបទបង្ហាញនៅតាម សាកលវិទ្យាល័យនានាក្នុងក្រុង ការផ្សព្វផ្សាយតាមរយៈការដាក់តាំងផ្ទាំងតារាងតម្លៃសេវាកម្មរបស់ការិយល័យច្រក ចេញចូលតែមួយធំៗនៅទីប្រជុំជនសាធារណៈ ការផ្តល់ព័ត៌មានតាមទូរស័ព្ទ និងតាមដោយផ្ទាល់មាត់ជាប្រចាំរាល់ ថ្ងៃធ្វើការ ។ ប្រជាពលរដ្ឋចំនួនប្រហែល ៧០%បានយល់ដឹងអំពីការិយាល័យច្រកចេញចូលតែមួយ ។

- **ការសម្របសម្រួល និងកិច្ចសហការជាមួយការិយាល័យជំនាញ**

មន្ត្រីនៃការិយាល័យជំនាញមានកិច្ចសហការល្អ។មន្ទីរវិស័យមួយចំនួនតូចហាក់ដូចជាមិនសូវផ្តល់នូវកិច្ចសហការល្អដែរ ។ ក្រៅពីនេះនៅមានការសម្របសម្រួលល្អជាមួយនឹងតំណាងការិយាល័យប្រជាពលរដ្ឋ ដែលមានវត្តមានជាប្រចាំនៅក្នុងការិយាល័យច្រកចេញចូលតែមួយ ជួយសម្របសម្រួលប្រជាពលរដ្ឋមកសុំសេវា។

- **ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្ស**

មន្ត្រីរាជការត្រូវប្រកាន់ខ្ជាប់ និងអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។ ប្រធានការិយាល័យច្រកចេញចូលតែមួយ បានធ្វើតារាងបែងចែកភារកិច្ចសម្រាប់សម្រាប់ការទទួលខុសត្រូវរបស់មន្ត្រីម្នាក់ៗ ។ ទោះជាយ៉ាងនេះក៏ដោយ មន្ត្រីគ្រប់រូបត្រូវជួយគ្នាទៅវិញទៅមក ដោយសារមិនមានមន្ត្រីគ្រប់គ្រាន់ បន្ថែមទៀត ក៏មាននិស្សិតស្ម័គ្រចិត្តមកយកបទពិសោធន៍ជួយបំពេញការងារផងដែរ។ ជាការលើកទឹកចិត្តមន្ត្រីត្រូវបានទទួលការបែងចែកភាគរយនៃប្រាក់ចំណូលដែលបានពីការផ្តល់សេវាកម្មផងដែរ។ ភាគរយនៃការបែងចែកនេះ ត្រូវផ្អែកទៅលើវត្តមានមកបំពេញការងារ លើលទ្ធផលការងារសម្រេចបានដែលឆ្លុះបញ្ចាំងតាមរយៈរបាយការណ៍បុគ្គលិកប្រចាំខែ ដែលត្រូវវាយតម្លៃដាក់សន្ទស្សន៍បុគ្គលិករៀងរាល់៣ខែម្តង ។ ការិយាល័យមិនមានរៀបចំឲ្យមានយន្តការបណ្តឹងសារទុក្ខសម្រាប់សម្របសម្រួលដោះស្រាយវិវាទរវាងបុគ្គលិកនិងបុគ្គលិកនោះទេ។ពាក់ព័ន្ធនឹងការបណ្តុះបណ្តាល ក្រសួងមហាផ្ទៃ និង ក្រសួងសាមីនីមួយៗមានភារកិច្ចរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រី ផ្អែកតាមកម្រិតប្រតិភូកម្មអំណាច តែពុំបានញឹកញាប់ទេ ប៉ុន្តែមន្ត្រីការិយាល័យច្រកចេញចូលតែមួយមួយចំនួន ក៏បានចូលរួមធ្វើការបណ្តុះបណ្តាលជាមួយមន្ត្រីរដ្ឋបាលក្រុង នូវកិច្ចការផ្សេងៗរបស់រដ្ឋបាលក្រុងទាំងមូលផងដែរ ។

- **ដំណើរការប្រចាំថ្ងៃរបស់ការិយាល័យ**

ការិយាល័យច្រកចេញចូលតែមួយ មិនមានផែនការប្រចាំខែទេ ប៉ុន្តែមានរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ក៏អាចឆ្លុះបញ្ចាំងពីកំណើនសេវាកម្មបានដែរដោយធ្វើការប្រៀបធៀបជាមួយបណ្តាឆ្នាំចាស់ ហើយរបាយការណ៍នេះ មួយសម្រាប់ជូនឲ្យមន្ទីរសាមី និងមួយទៀតសម្រាប់ធ្វើទៅរដ្ឋបាលក្រុង។ ករណីមានបញ្ហាមិនប្រក្រតីកើតឡើង ប្រធានការិយាល័យច្រកចេញចូលតែមួយ បានដោះស្រាយភ្លាម។

- **ការតាមដានត្រួតពិនិត្យ**

តំណាងការិយាល័យប្រជាពលរដ្ឋធ្វើការស្ទាបស្ទង់មតិរបស់ប្រជាពលរដ្ឋជាប្រចាំដោយប្រើប្រាស់ទម្រង់បញ្ចេញមតិ ដាក់នៅក្នុងប្រអប់ផ្តល់មតិយោបល់នៅក្នុងការិយាល័យច្រកចេញចូលតែមួយ និងនៅតាមទីសាធារណៈមួយចំនួន។

៣. មេរៀនបទពិសោធន៍

ការផ្សព្វផ្សាយអំពីការផ្តល់សេវារបស់ការិយាល័យច្រកចេញចូលតែមួយបានទូលំទូលាយ ការផ្តល់សេវាមានតម្លាភាព ដូចជាការយកកម្រៃសេវាតាមការកំណត់ និងមានវិក្កយបត្រច្បាស់លាស់ បានធ្វើឲ្យប្រជាពលរដ្ឋ មានទំនុកចិត្ត។មានការប្រមូលយោបល់ត្រឡប់ពីរបស់ប្រជាពលរដ្ឋ ហើយបានចែករំលែកព័ត៌មានទាំងនោះ ទៅដល់ មន្ត្រីជាប្រចាំ ដើម្បីធ្វើការកែតម្រូវនូវអ្វីដែលមិនប្រក្រតីជាបណ្តើរៗ ។ ទន្ទឹមនឹងនេះក៏មានបញ្ហាប្រឈមមួយចំនួន ដូចជាការធ្វើប្រតិភូកម្មនៅមានចន្លោះប្រហោងដូចជា វិស័យសំណង់ វិស័យអប់រំ វិស័យទេសចរណ៍ និង វិស័យឧស្សាហកម្មនិងសិប្បកម្មជាដើម ។ល។

ការិយាល័យច្រកចេញចូលតែមួយមានទំហំតូចចង្អៀត ឯកសារចេះ តែកើនច្រើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ហើយគ្រឿងប្រើប្រាស់អេឡិចត្រូនិក ដូចជាម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនព្រីនធ័រ និងម៉ាស៊ីនហ្វូតូកូពី កាន់តែចាស់ៗ និង

ដំណើរការទាំងលំបាក ។ ដូចនេះសម្ភារៈចាស់ៗ ឬលែងដំណើរការគួរផ្លាស់ប្តូរចេញ កន្លែងទុកដាក់ឯកសារត្រូវតែរៀបចំបន្ថែមទៀត ទម្រង់លិខិតចម្លងអត្រានុកូលដ្ឋានពេលខ្លះពុំមានគ្រប់គ្រាន់តាមតម្រូវការរបស់ប្រជាពលរដ្ឋ ដូច្នេះត្រូវមានកិច្ចសហការល្អពីថ្នាក់ដឹកនាំមន្ទីរវិស័យជំនាញនានា ពីរដ្ឋបាលក្រុងខេត្ត និងក្រសួងផងដែរ។

៤. ការគាំទ្រ

ក្នុងអំឡុងពេលអនុវត្តគម្រោងសាកល្បង មូលនិធិខុនរ៉ាដបានត្រួសត្រាយផ្លូវ និងបានបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រី ក៏ដូចជាថ្នាក់ដឹកនាំ។ បន្ទាប់មកទៀត ធនាគារពិភពលោកបានផ្តល់សម្ភារៈប្រើប្រាស់ ក្នុងការិយាល័យ ផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែដល់មន្ត្រី ផ្តល់ថ្លៃសាំងធ្វើដំណើរសម្រាប់ចុះអង្កេតទីតាំងធ្វើអាជីវកម្ម ដែលជម្រុញឲ្យមានដំណើរការដោយរលូន និងមានការពេញចិត្តពីសំណាក់ប្រជាពលរដ្ឋ ឬអ្នកប្រើប្រាស់សេវា និង មន្ត្រីការិយាល័យច្រកចេញចូលតែមួយផងដែរ។

៥. ការផ្លាស់ប្តូរមេរៀនបទពិសោធន៍

ការផ្តល់សេវាតាមរយៈការិយាល័យច្រកចេញចូលតែមួយគឺជាយន្តការល្អដោយបានឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋបានលឿន។ ដើម្បីឲ្យយន្តការ ឬ ការិយាល័យនេះដំណើរការកាន់តែល្អ សកម្មភាពចាំបាច់មួយចំនួនត្រូវតែអនុវត្ត៖

- ផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីសេវាផ្តល់ដោយការិយាល័យច្រកចេញចូលតែមួយ ជូនដល់ប្រជាពលរដ្ឋ អាជីវករ ពាណិជ្ជករ ធុរជន។
- សិក្សាទីតាំងភូមិសាស្ត្រ និងស្រង់ទិន្នន័យក្រុងស្រុកនិងអាជីវកម្ម សេវាកម្មនានា ឲ្យបានល្អិតល្អន់
- បណ្តុះបណ្តាលមន្ត្រីគ្រប់ផ្នែកទាំងអស់ ទាំងជួរមុខ និងជួរក្រោយ
- មន្ត្រីត្រូវយល់ដឹងឲ្យបានច្បាស់លាស់អំពីច្បាប់គតិយុត្តិរបស់ការិយាល័យច្រកចេញចូលតែមួយ។
- ធ្វើទស្សនកិច្ចសិក្សានៅតាមការិយាល័យច្រកចេញចូលតែមួយដែលបានបង្កើតមុន
- បែងចែកភារកិច្ចនិងការទទួលខុសត្រូវដល់មន្ត្រីឲ្យបានច្បាស់លាស់ និងគោរពតាមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលឲ្យបានត្រឹមត្រូវ ។
- ត្រូវមានសហការល្អគ្រប់ផ្នែកពាក់ព័ន្ធ ។

****

ការិយាល័យច្រកចេញចូលតែមួយ ស្រុកមោងឫស្សី ខេត្តបាត់ដំបង

1. សាវតា Background:

ស្រុកមោងឫស្សី ជាស្រុកមួយក្នុងចំណោមក្រុង-ស្រុក ទាំង១៤ របស់ខេត្តបាត់ដំបង ស្ថិតនៅតាមបណ្តោយ ផ្លូវជាតិលេខ៥ ចំងាយ៤៦គីឡូម៉ែត្រ ពីខេត្តបាត់ដំបង។ បែងចែកជារដ្ឋបាលឃុំចំនួន៩ឃុំ មានភូមិចំនួន៩២ភូមិចំណុះ មានគ្រួសារប្រជាពលរដ្ឋចំនួន២៦,៤៦២គ្រួសារ មនុស្សរាយចំនួន១២១,៥៨៨នាក់ ក្នុងនោះស្រី៦១,៤៥៤នាក់។ ការិយាល័យច្រកចេញចូលតែមួយ បានចាប់ផ្តើម ដំណើរការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ ចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ២០១៧។

2. ប្រតិបត្តិការ Operation:

ការផ្សព្វផ្សាយការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៃស្រុកមោងឫស្សី នៅពុំទាន់បានទូលំទូលាយនៅឡើយ កន្លងមកមានតែការផ្សព្វផ្សាយតាមរយៈការប្រជុំផ្ទៃក្នុង ដោយឡែកការចុះផ្សព្វផ្សាយដល់មូលដ្ឋាន ការធ្វើសកម្មភាព ឬ យុទ្ធនាការផ្សព្វផ្សាយជូនប្រជាពលរដ្ឋ និងអាជីវករឲ្យបានយល់ដឹងអំពីការផ្តល់សេវាដោយការិយាល័យច្រកចេញចូលតែមួយ និងការដាក់តាំងផ្ទាំងផ្សព្វផ្សាយអំពីប្រភេទ និងតម្លៃសេវានៅតាមទីសាធារណៈនៅមិនទាន់បានរៀបចំនៅឡើយ។ តែក៏បានផ្សព្វផ្សាយគោលៗពីតួនាទីរបស់ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សានាពេលកន្លងទៅដែរ។ បច្ចុប្បន្ន ការិយាល័យនេះកំពុងសហការជាមួយកម្មវិធីGIZ/DARធ្វើការសិក្សាអំពីវិធីសាស្ត្រផ្សព្វផ្សាយឲ្យមានប្រសិទ្ធិភាពតាមរយៈការប្រឹក្សាយោបល់។

ការិយាល័យច្រកចេញចូលតែមួយបានសម្របសម្រួលជាមួយការិយាល័យ និងមន្ទីរជំនាញ ក្នុងការរៀបចំទម្រង់ពាក្យស្នើសុំសេវា ឯកសារភ្ជាប់ អាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាត។ ដោយឡែកការិយាល័យនេះនៅមិនទាន់មានទំនាក់ទំនង និងសម្របសម្រួលដើម្បីទទួលបាន ការគាំទ្រពីអង្គការក្រៅរដ្ឋកិបាលផ្សេងទៀត ក៏ដូចជាវិស័យឯកជននៅឡើយទេ។ *ចំពោះការ*សម្របសម្រួលជាមួយការិយាល័យប្រជាពលរដ្ឋ ការិយាល័យនេះនៅមិនទាន់បានធ្វើឲ្យអោយបានពេញលេញនៅឡើយទេដោយសារ មិនមានជាបណ្តឹងតវ៉ាពាក់ព័ន្ធនឹងការផ្តល់សេវា តែកន្លងមកមានការជជែកគ្នាខ្លះពីតម្រូវការរបស់អ្នកមកទទួលសេវា ដូចជាៈ ប្រជាពលរដ្ឋមិនទាន់យល់ដឹងពីការិយាលច្រកតែមួយ គាត់មានសំនួរច្រើនពាក់ពន្ធ័នឹងសេវាដែលមាននៅក្នុងការិយាល័យច្រក។

ពាក់ព័ន្ធនឹងការរៀបចំការពិពណ៌នាមុខតំណែងការិយាល័យច្រកចេញចូលស្រុកមោងឬស្សីពុំទាន់មាន និង/ឬពុំទាន់មានការចុះហត្ថលេខាទទួលស្គាល់លើការពិពណ៌នាមុខតំណែងពីសំណាក់មន្ត្រីម្នាក់ៗនៅ ឡើយ។ ការវាយតម្លៃបុគ្គលិកដែលបំពេញការងារ នៅក្នុងការិយាល័យច្រកចេញចូលតែមួយនៃស្រុកមោង ឬស្សីធ្វើឡើងរៀងរាល់មួយខែម្តង។ ចំពោះនីតិវិធីនៃការអនុម័តផ្តល់ប្រាក់រង្វាន់លើទឹកចិត្តដល់បុគ្គលិក ត្រូវ បានបំពេញតាមនីតិវិធី និងការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តិ (ការប្រជុំជាមួយនាយករដ្ឋបាល ការ ឯកភាពពីគណៈអភិបាល និងការអនុម័តដោយក្រុមប្រឹក្សា)។ មន្ត្រីទាំងអស់ត្រូវបានទទួលការបណ្តុះ បណ្តាលស្តីពី ការអនុវត្តការងាររបស់ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ។

ការតាមដានគុណភាពការផ្តល់សេវា៖ ការិយាល័យបានបិទផ្សព្វផ្សាយពីប្រភេទសេវា ពេលវេលា និងតម្លៃសេវា ក្នុងនោះដែរក៏មានមន្ត្រីជួរមុខសម្រាប់ផ្តល់ព័ត៌មាន និងមានមន្ត្រីជួរក្រោយតាមការិយាល័យ ជំនាញជាអ្នកផ្តល់សេវាតាមប្រភេទសេវាដែលប្រជាពលរដ្ឋត្រូវការ ហើយរាល់ការផ្តល់សេវាត្រូវចេញវិក័យ បត្រថ្លៃសេវា។

ពាក់ព័ន្ធនឹងការស្វង់មតិរបស់ប្រជាពលរដ្ឋ៖ ត្រូវបានធ្វើឡើងដោយប្រើប្រាស់យន្តការការិយាល័យប្រជា ពលរដ្ឋ តាមរយៈវិធីសាស្ត្រផ្សេងៗដូចជា ប្រអប់សំបុត្រទទួលពាក្យបណ្តឹង មានប្រអប់សំបុត្រ និងទម្រង់ស្វង់មតិ របស់ប្រជាពលរដ្ឋ ការទទួលបណ្តឹងផ្ទាល់មាត់ តាមរយៈប្រព័ន្ធទូរស័ព្ទ និងប្រព័ន្ធបណ្តាញសង្គម។

3. បទពិសោធន៍ Lesson Learnt

ចំនុចល្អសម្រាប់ការិយាល័យច្រកចេញចូលតែមួយ៖ មានទីតាំង អគារ ឧបករណ៍ សម្ភារៈ ប្រព័ន្ធ បណ្តាញInternet សមស្របតាមតម្រូវការ និងមាន មន្ត្រីជួរមុខ មន្ត្រីជួរក្រោយ និងមន្ត្រីរដ្ឋបាលស្រុក សហ ការគ្នាក្នុងការបម្រើសេវាជូនប្រជាពលរដ្ឋ។ ទោះបីយ៉ាងណាក៏យើងនូវមានបញ្ហាប្រឈមជាមួយចំនួនដែល ត្រូវយកចិត្តទុកដាក់ដូចជា៖ ១) មិនទាន់មានការណែនាំច្បាស់លាស់អំពីទម្រង់ និងនីតិវិធី សម្រាប់ប្រជា ពលរដ្ឋ ដែលបាន មកទទួលសេវា(ការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ)។ ២) ប្រជាពលរដ្ឋដែលត្រូវការស្នើ សុំលិខិតអនុញ្ញាតសាងសង់ ដែលមិនមានគំនូសបូង៌ស្ថាបត្យកម្ម ការិយាល័យ និងមន្ទីររៀបចំដែនដីនគរូប នីយកម្ម សំណង់ និងសូរិយោដីខេត្ត កំណត់ឲ្យមានបូង៌ស្ថាបត្យកម្មភ្ជាប់ទើបឯកភាពឲ្យរដ្ឋបាលស្រុក ចេញ លិខិតអនុញ្ញាតជូនគាត់ ទោះបីសំណង់តូច ឬធំ។ ៣)សេវាអត្រានុកូលដ្ឋាន និងឋិតចម្ងង់ឯកសារនានា មាន ចំនួនច្រើន ហើយភាគច្រើនគឺត្រូវការប្រញ៉ាប់។**៤**)មន្ត្រីជួរមុខមានចំនួនតិច(៣នាក់) មិនអាចទ្រាំទ្រនិង ការងារផ្នែកជួរមុខដែលមានច្រើនបានទេ។ **៥**)ខ្វះមន្ត្រីជួរក្រោយផ្នែកសិប្បកម្មនិងឧស្សាហកម្ម និងផ្នែកវ៉ៃ និងថាមពល។ **៦**)មន្ត្រីជួរក្រោយមួយចំនួនគ្មានបទពិសោធន៍និងបច្ចេកទេសជំនាញដែលខ្លួនត្រូវអនុវត្តន៍។

ចំពោះសេវាដែលពាក់ព័ន្ធច្រើនជំនាញ គួតែក្រសួងឬមន្ទីរជំនាញសហការគ្នារៀបចំសេចក្ដីណែនាំ និងទម្រង់បែបបទ ឲ្យបានសមស្របសម្រាប់អ្នកស្នើសុំសេវា។ ដាក់បញ្ចូលសេវាតម្រូវការចាំបាច់ផ្សេងៗដែលឯកជនជាអ្នកផ្ដល់សេវាឲ្យរដ្ឋបាលជាអ្នកធ្វើវិញដូចជាសេវាគូសបង្ហ័ស្ដាបត្យកម្ម សណ្ឋាប័ត្រក្បាលដីជាដើម។

4. ការគាំទ្រ Support:

ជាទូទៅរដ្ឋបាលស្រុកជាអ្នកសម្របសម្រួល និងដោះស្រាយបញ្ហាប្រឈម ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ស្រុក ចំពោះបញ្ហាប្រឈមដែលហួសសមត្ថកិច្ចរបស់ស្រុកមិនទាន់មានការសម្របសម្រួលឲ្យបានសមស្របនៅឡើយទេ។ការិយាល័យនេះមានតម្រូវការគាំទ្រនាពេលអនាគតលើយុទ្ធនាការផ្សព្វផ្សាយ ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេសដល់មន្ត្រីជួរក្រោយ ជួរមុខ គាំទ្រដល់ការវាយតម្លៃអំពីគុណភាពសេវា គាំទ្រក្នុងការសម្របសម្រួលរវាងការិយាល័យច្រក និងការិយាល័យ មន្ទីរ អង្គភាពជំនាញជាដើម។ ទន្ទឹមនឹងនោះក៏ទាមទារឲ្យមន្ត្រី និងការិយាល័យជំនាញចុះជម្រុញ និងត្រួតពិនិត្យបន្ថែមទើបជោគជ័យ។

5. ចែករំលែកបទពិសោធន៍ Experience Exchange:

ចំពោះស្រុកដែលត្រូវបង្កើតការិយាល័យ ឬ យន្តការការិយាល័យច្រកចេញចូលតែមួយ គួរតែត្រៀមរៀបចំមន្ត្រីជួរមុខ និងស្នើសុំមន្ត្រីជួរក្រោយពីមន្ទីរជំនាញពាក់ព័ន្ធ។គួររៀបចំទីកន្លែង ឬអគារ និងឧបករណ៍សម្ភារៈ ប្រព័ន្ធបណ្ដាញInternet ឲ្យបានសមស្រប។ គួរតែរៀបចំឲ្យមានមន្ត្រីចុះកម្មសិក្សា នៅតាមការិយាល័យច្រកចេញចូលតែមួយ ដើម្បីរៀនសូត្រដកស្រង់បទពិសោធន៍ ការនុវត្តន៍ផ្ទាល់។

ការអនុវត្តការផ្ទេរមុខងារ

- ឆ្លងតាមការពិភាក្សាអំពីដំណោះស្រាយការបង្ហូរកាកសំណល់ចូលស្រែប្រជាពលរដ្ឋ និងកូនសួយពីកសិដ្ឋានចិញ្ចឹមជ្រូកនៅឃុំកំពុងស្វាយ តើលោក'លោកស្រីគិតថាការអនុវត្តមុខងារបែបនេះ ជាប្រភេទមុខងារអ្វីដែរ?
- ហេតុអ្វីបានជាមុខងារជាជម្រើសមានសារៈសំខាន់?
- តើលោក លោកស្រីគួរមានផែនការអ្វីខ្លះដើម្បីអនុវត្តមុខងារជាជម្រើសនេះ នៅពេលត្រលប់ទៅកន្លែងការងារវិញ?

សំណួរឆ្លុះបញ្ចាំងសម្រាប់ថ្ងៃទី០២

- លោក លោកស្រីបានរៀនសូត្រអ្វីខ្លះពីឧទាហរណ៍ខាងលើនេះ?
- តើឧទាហរណ៍ខាងលើនេះមានសារៈសំខាន់អ្វីខ្លះដល់ការងាររបស់ថ្នាក់ជាតិ?
- តើឧទាហរណ៍ខាងលើនេះមានសារៈសំខាន់អ្វីខ្លះដល់ការងាររបស់ថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់ក្រុង និងស្រុក?
- តើថ្នាក់ជាតិ (គ.ជ.អ.ប. និងក្រសួងមុខងារសាធារណៈ)អាចជួយគាំទ្រដល់ក្រុមប្រឹក្សា និងរដ្ឋបាលថ្នាក់ក្រោមជាតិយ៉ាងដូចម្តេចដែរ?
- តើថ្នាក់ក្រោមជាតិត្រូវការការគាំទ្រអ្វីខ្លះពីថ្នាក់ជាតិ?

Co-funded by the European Union

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

គជអប
NCDD

សិក្ខាសាលាផ្លាស់ប្តូរមេរៀនបទពិសោធន៍ លើកទី២
អំពី
ការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន និងមុខងារជាជម្រើស

2nd Learning Exchange Workshop
on
Local Economic Development (LED)
and Permissive Functions

ថ្ងៃទី ៥ - ៦ ខែធ្នូ ឆ្នាំ២០១៧
ខេត្តបាត់ដំបង

5th - 6th December 2017
Battambang Province

Co-funded by the European Union

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

គជអប NCDD

សិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍
ស្តីពី
ការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន និងមុខងារជាជម្រើស
គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល

(EU DAR)

ក្រោមកិច្ចសហការជាមួយគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ (RED III)
ថ្ងៃទី ៥ - ៦ ខែធ្នូ ឆ្នាំ២០១៧
សណ្ឋាគារខេមរា ខេត្តបាត់ដំបង

---

១. សេចក្តីផ្តើម

រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាស្ថាប័នរបស់រដ្ឋាភិបាលដែលនៅកៀកនឹងប្រជាពលរដ្ឋ ហើយរដ្ឋបាលនេះមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋរបស់ខ្លួន។ អ្នករៀបចំធ្វើគោលនយោបាយនៅប្រទេសកម្ពុជាបានយល់ច្បាស់ពីភាពចាំបាច់នៃការចូលរួមយ៉ាងជិតស្និទ្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរមុខងារ និងអំណាចដល់រដ្ឋបាលថ្នាក់មូលដ្ឋានដើម្បីផ្តល់សេវាបានល្អប្រសើរនិងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។ ទោះជាយ៉ាងនេះក៏ដោយ ដំណើរការវិមជ្ឈការគឺត្រូវចំណាយវេលាពេលច្រើន ហើយធនធានទៀតសោតក៏មិនទាន់ត្រូវបានបែងចែងទៅតាមផែនការដែលបានគ្រោងទុកនៅឡើយ។

